# សេរីភាពនៃការបង្កើតសមាគម

## ក. មុខងារនៃសមាគមសេរី

មនុស្សលោកមានចំណុចខ្សោយជាច្រើនក្នុងការដោះស្រាយបញ្ហារបស់ខ្លួនតែឯង នៅក្នុងករណីជាច្រើន ។ ដូច្នេះ ពួកគេត្រូវការជាចំបាច់នូវការទំនាក់ទំនង និងធ្វើការជាមួយគ្នា ដើម្បីដោះស្រាយបញ្ហារួមរបស់ពួកគេ ។ ពួកគេតែងតែធ្វើការជាមួយគ្នាជាក្រុម ពីព្រោះតាមរយៈការធ្វើបែបនេះ ពួកគេអាចប្រមូលផ្តុំនូវសមត្ថភាព និងកម្លាំងផ្សេងៗគ្នាបាន ។ ការធ្វើការរួមគ្នាជាក្រុមដែលមានការរៀបចំល្អនេះ ធ្វើឱ្យសមាជិកម្នាក់ៗនៃអង្គការចាត់តាំងនេះមានកម្លាំងកាន់តែខ្លាំងឡើង ៖ សមាជិកក្រុមទាំងឡាយអាចទទួលអត្ថប្រយោជន៍ ពីបទពិសោធន៍ ការគាំទ្រ និងការការពារដល់សមាជិកផ្សេងៗទៀតនៃក្រុម ហើយអាចចែករំលែកគំនិតយោបល់ពីគ្នាទៅវិញទៅមកបាន ។ មនុស្សម្នាក់គេអាចវាយប្រហារបានដោយងាយ ប៉ុន្តែមនុស្សមួយក្រុមគេមិនងាយវាយប្រហារបានដោយស្រួលឡើយ ។

សូមមើលបាវចនា:

"សាមគ្គីរស់ បែកបាក់សាមគ្គីស្លាប់"

ឬពាក្យស្លោកថា:

"ចង្កឹះមួយអ្នកអាចកាច់បាក់បាន ប៉ុន្តែចង្កឹះមួយបាច់ អ្នកមិនអាចកាច់បានឡើយ"



ដូច្នេះ ការបង្កើតសមាគមមួយ គឺជាមធ្យោបាយដ៏មានឥទ្ធិពលបំផុតសំរាប់មនុស្សទាំងអស់ ដើម្បីជំរុញប្រយោជន៍រួមរបស់ពួកគេឱ្យជឿនលឿនទៅមុខ និងដើម្បីដោះស្រាយបញ្ហាសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ វប្បធម៌ ឬបញ្ហាផ្សេងទៀតណាមួយរបស់ពួកគេ ។ អាស្រ័យហេតុនេះទើប ៖

- កម្មករបង្កើត **សហជីពកម្មករ** ដើម្បីតស៊ូទាមទារសិទ្ធិ និងផលប្រយោជន៍កម្មកររបស់ខ្លួន
- ប្រជាពលរដ្ឋបង្កើត **គណបក្សនយោបាយ** ដើម្បីពង្រឹងផលប៉ះពាល់នៃទស្សនៈនយោបាយរួមរបស់ខ្លួន
- និស្សិតបង្កើត **សមាគមនិស្សិត** ឬគ្រូបង្រៀនបង្កើត **សមាគមគ្រូបង្រៀន** ដើម្បីធ្វើឱ្យគេបានដឹងអំពីកង្វល់របស់ខ្លួន
- ប្រជាជនបង្កើត **អង្គការមិនមែនរដ្ឋាភិបាល** ដើម្បីដោះស្រាយបញ្ហាសង្គមរួម ដូចជា ការជួយដល់ប្រជាជនក្រីក្រ ការគាំទ្រសិទ្ធិមនុស្ស ការការពារបេតិកភណ្ឌវប្បធម៌ ឬបរិស្ថាន
- ប្រជាជនបង្កើតសមាគមផ្សេងៗ ដូចជា **ក្លឹបកីឡា** ឬ **ក្លឹបវប្បធម៌** ដើម្បីបានសប្បាយរីករាយ និងរៀបចំ ល្បែងកីឡា ឬព្រឹត្តិការណ៍ផ្សេងៗ ដែលពួកគេមានចំណាប់អារម្មណ៍ជារួម
- ពាណិជ្ជករបង្កើត**ក្រុមហ៊ុន** ដើម្បីប្រមូលផ្តុំសមត្ថភាពផ្នែកសេដ្ឋកិច្ចរបស់ពួកគេក្នុងគោលបំណងសម្រេចបាននូវកម្រៃរួមមួយ ( ដូចជា អ្នកនេសាទប្រមូលផ្តុំគ្នានៅក្នុងសហគមន៍នេសាទ) ។

សកម្មភាពទាំងអស់នេះត្រូវបានលើកទឹកចិត្តដោយមាត្រា ៣៥ I នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ៖

> មាត្រា៣៥ I CC:
>
> ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិ ចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ។

## ខ. ការការពារផ្លូវច្បាប់ចំពោះសេរីភាពនៃការបង្កើតសមាគម៖

ដើម្បីការពារសេចក្ដីត្រូវការជាមូលដ្ឋានរបស់មនុស្សសំរាប់ការបង្កើតក្រុមណាមួយ ច្បាប់ធានានូវ**សិទ្ធិមនុស្សជាមូលដ្ឋាន** ចំពោះ**សេរីភាពនៃការបង្កើតសមាគម** ។

សិទ្ធិនេះ គឺជាសិទ្ធិមួយក្នុងចំណោមសិទ្ធិនយោបាយ និងស៊ីវិលដ៏សំខាន់បំផុតជាច្រើនទៀត ពីព្រោះវាអាចធ្វើឱ្យប្រជាជនធ្វើសកម្មភាពក្នុងមធ្យោបាយមួយដ៏រឹងមាំ និងមានឥទ្ធិពលដោយឯករាជ្យ លើអត្ថប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេនៅខាងក្រៅរចនាសម្ព័ន្ធចាត់តាំងរបស់រដ្ឋ និងរដ្ឋាភិបាល នៅក្នុងផ្ទៃកងកជន ។

ដូច្នេះ វាមានសារៈសំខាន់ណាស់ដើម្បីគូសបញ្ជាក់ថា សេរីភាពនៃការបង្កើតសមាគមគឺជា**សិទ្ធិពីកំណើតរបស់មនុស្សគ្រប់រូប** ហើយ**វាមិនមែនគ្រាន់តែជាបុព្វសិទ្ធិដែលរដ្ឋអាច** ឬមិនអាចផ្ដល់ឱ្យតាមឆន្ទានុសិទ្ធិរបស់ខ្លួនឡើយ ។ ដូច្នេះ **ពុំមានការចាំបាច់ណាមួយ ដើម្បីសុំការអនុញ្ញាតបង្កើតសមាគមឡើយ** ប៉ុន្តែប្រជាជនអាចជ្រើសរើសធ្វើដូច្នេះបាន[៥០] ។ (ចំណាំ ៖ ការចុះបញ្ជីការសមាគមជាញឹកញាប់តម្រូវដោយច្បាប់ផ្សេងៗពីគ្នា ប៉ុន្តែ ការចុះបញ្ជីនេះគ្រាន់តែជូនដំណឹងដល់អាជ្ញាធរ និងកំណត់នូវទំរង់បែបបទមួយចំនួនប៉ុណ្ណោះ ។ ការដាក់ពាក្យសុំចុះបញ្ជី គឺមិនមែនមានន័យថា ជាការសុំការអនុញ្ញាតទេ!)៖

> ឧទាហរណ៍៖
>
> នៅពេលដែលគ្រូបង្រៀនកម្ពុជាមានបំណងបង្កើតសមាគមគ្រូបង្រៀនឯករាជ្យ អាជ្ញាធរបានព្យាយាមរារាំងមិនឱ្យពួកគេជួបប្រជុំគ្នា និងបោះឆ្នោតជ្រើសរើសប្រធានសមាគម ។ អាជ្ញាធរបានអះអាងថា គ្រូបង្រៀនទាំងនេះត្រូវសុំការអនុញ្ញាតពីក្រសួងមហាផ្ទៃ ដើម្បីរៀបចំការប្រជុំនេះ ប៉ុន្តែពួកគេមិនបានបំពេញកាតព្វកិច្ចនេះ ។ ទង្វើបែបនេះរបស់អាជ្ញាធរ មិនស្របតាមរដ្ឋធម្មនុញ្ញឡើយ ពីព្រោះ សេរីភាពនៃការបង្កើតសមគមមិនត្រូវការការអនុញ្ញាតដើម្បីអនុវត្តទេ ។ ហេតុនេះហើយបានជា ពង្រាងច្បាប់ស្ដីពីការបង្កើតសមាគមរបស់ប្រទេសកម្ពុជា (មាត្រា ៦) ចែងផងដែរថា មានតែករណីយកិច្ចដើម្បី ជូនដំណឹង ដល់អាជ្ញាធរអំពីការបង្កើតសមាគម និងការចុះបញ្ជីឈ្មោះតែប៉ុណ្ណោះ ប៉ុន្តែវាមិនបានតម្រូវឱ្យសុំការអនុញ្ញាតណាមួយឡើយ!

ការការពារសេរីភាពនៃការបង្កើតសមាគម មានចែងនៅក្នុងអត្ថបទច្បាប់ផ្សេងៗទៀតជាច្រើន ៖

> មាត្រា៤២ I ១ CC:
>
> ប្រជាពលរដ្ឋខ្មែរមាន សិទ្ធិដើម្បីបង្កើតសមាគម និងគណបក្សនយោបាយ ។

---

[៥០] ឧទាហរណ៍៖ មាត្រា២ នៃអនុសញ្ញា ILO ស្ដីពីសេរីភាពនៃការបង្កើតសមាគមចែងយ៉ាងច្បាស់ថា កម្មករអាចបង្កើតសហជីពបាន "ដោយពុំចាំបាច់សុំការអនុញ្ញាតជាមុន" (មើលវិបសាយ ៖ www.hrni.org ៖ ចុចលើ "rights and freedoms" បន្ទាប់មកចុចលើ "freedom of reunion and association" ហើយបន្ទាប់មកទៀត ចុចលើ "specific instrument" ។)

មាត្រា២២ I ICCPR:

មនុស្សគ្រប់រូប មានសិទ្ធិទទួលបានសេរីភាពនៃការបង្កើតសមាគមជាមួយអ្នកដទៃទៀត ដោយរាប់បញ្ចូលទាំងសិទ្ធិក្នុងការបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ។

ចំពោះ **ស្ត្រី កុមារ** និង **ជនជាតិភាគតិច** មានឯកសារច្បាប់ជាច្រើនផ្សេងទៀត ដែលធានាបន្ថែមថា ក្រុមទាំងនេះ ក៏មាន និងអនុវត្តសិទ្ធិមនុស្សរបស់ខ្លួនក្នុងការបង្កើតសមាគមដោយសេរីយ៉ាងពិតប្រាកដផងដែរ ។

មាត្រា១៤ II ង នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីភេទ (CEDAW) :

... រដ្ឋភាគីត្រូវចាត់វិធានការសមស្រប ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងស្ត្រីភេទ នៅតាមតំបន់ជនបទ ដើម្បីធានាថា ពួកគេបានចូលរួម និងទទួលអត្ថប្រយោជន៍ពីការអភិវឌ្ឍន៍ជនបទដោយផ្អែកលើមូលដ្ឋានស្មើភាពគ្នារវាងបុរស និងស្ត្រី និងជាពិសេសត្រូវធានាចំពោះស្ត្រីទាំងនោះ នូវសិទ្ធិ :

... (ង) បង្កើតក្រុមជួយខ្លួនឯង និងសហករ ដើម្បីទទួលបានភាពស្មើគ្នាចំពោះកាលានុវត្តិភាពផ្នែកសេដ្ឋកិច្ច តាមរយៈ ការងារ ឬការការបំពេញការងារដោយខ្លួនឯង ។ ផ្សេង**...**

មាត្រា ១៥ I នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ (CRC):

រដ្ឋជាភាគីទទួលស្គាល់**នូវសិទ្ធិកុមារក្នុងការទទួលបានសេរីភាពនៃការបង្កើតសមាគម** និងសេរីភាពនៃការប្រមូលផ្តុំគ្នាដោយសន្តិវិធី ។

មាត្រា ៥ ឃ (ix) អនុសញ្ញាអន្តរជាតិស្តីពីការលុបបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងពូជសាសន៍ (CERD):

ដោយអនុវត្តតាមកាតព្វកិច្ចជាមូលដ្ឋានដែលមានចែងនៅក្នុងមាត្រា២ នៃអនុសញ្ញានេះ រដ្ឋជាភាគីទាំងឡាយ ធានាហាមប្រាម និងលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ និងដើម្បីធានានូវសិទ្ធិរបស់បុគ្គលគ្រប់រូប ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ឬដើមកំណើតជាតិ ឬជនជាតិ ឱ្យមានភាពស្មើគ្នាចំពោះមុខច្បាប់ក្នុងការទទួលបានសិទ្ធិដូចខាងក្រោម :

ឃ. សិទ្ធិស៊ីវិលផ្សេងៗទៀតជាពិសេសៈ សិទ្ធិទទួលបានសេរីភាពនៃការប្រមូលផ្តុំគ្នាដោយសន្តិវិធី និងការបង្កើតសមាគមម ។

មាន**ការធានាជាពិសេស**ផ្លូវច្បាប់ សំរាប់សិទ្ធិក្នុងការបង្កើត**សហជីពកម្មករ**ផងដែរ ។ (នៅក្នុង ICCPR សិទ្ធិនេះត្រូវបានបញ្ចូលយ៉ាងច្បាស់លាស់ទៅក្នុងសិទ្ធិទទួលបានសេរីភាពនៃការបង្កើតសមាគម មាត្រា ២២ Nr.១ ICCPR ខាងលើ) ។

មាត្រា៣៦ V CC:

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមាន សិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ ។

មាត្រា ៥ (ង) (ii) ICERD:

ដោយគោរពតាមកាតព្វកិច្ចជាគ្រឹះដែលបានលើកឡើងនៅក្នុងមាត្រា២ នៃអនុសញ្ញានេះ រដ្ឋជាភាគីទាំងឡាយ ត្រូវហាមឃាត់ និងលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍គ្រប់បែបយ៉ាងទាំងអស់ ហើយត្រូវធានាផ្តល់ឱ្យបុគ្គលម្នាក់ៗនូវសិទ្ធិស្មើភាពនៅចំពោះមុខច្បាប់ ដោយឥតបែងចែករវាង ភេទ ពណ៌សម្បុរ សញ្ជាតិ ឬជនជាតិណាឡើយ ជាពិសេសក្នុងការអាស្រ័យផលនៃសិទ្ធិទាំងឡាយ ដូចខាងក្រោមនេះ: ... (ង)សិទ្ធិផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ជាពិសេស... (ii) សិទ្ធិបង្កើត និងចូលជាសមាជិកសហជីពពាណិជ្ជកម្ម ...

មាត្រា ៨ I (ក) អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ICESCR):

រដ្ឋទាំងឡាយដែលជាភាគីនៃកតិកាសញ្ញានេះ ត្រូវធានាឱ្យបាននូវ :

(ក) សិទ្ធិរបស់មនុស្សដើម្បីបង្កើតសហជីពឬចូលរួមជាមួយសហជីពណាមួយតាមឆន្ទះរបស់គេ ដើម្បី បណ្តុះបណ្តាល និងការពារផលប្រយោជន៍របស់គេក្នុងវិស័យសង្គម និងសេដ្ឋកិច្ច ។

អង្គការការងារអន្តរជាតិ (ILO) មាត្រា២ អនុសញ្ញាស្តីពីសេរីភាពនៃការបង្កើតសមាគម និងការការពារសិទ្ធិក្នុងការរៀបចំ (១៩៤៨):

កម្មករ និងនិយោជក ដោយគ្មានការបែងចែក មានសិទ្ធិដើម្បីបង្កើត និង ដើម្បី ចូលជាសមាជិកនៃអង្គការទាំងឡាយតាមឆន្ទៈរបស់ខ្លួន ដោយពុំមានការអនុញ្ញាតជាមុនឡើយ ដោយត្រូវគោរពតាមតែបទបញ្ជារបស់អង្គការពាក់ព័ន្ធប៉ុណ្ណោះ ...

(អត្ថបទទាំងមូលនៃអនុសញ្ញានេះមានផ្សព្វផ្សាយនៅក្នុងអ៊ិនធើណិត[៥១] ។)

## គ. ធាតុរបស់ "សិទ្ធិទទួលបានសេរីភាពក្នុងការបង្កើតសមាគម"

### ១. តើពាក្យថា "**សមាគម**" មានន័យដូចម្តេច?

សមាគមមួយគឺជា

- ក្រុម នៃមនុស្ស

ពាក្យ "ក្រុម" ឬ "សមាគម" តម្រូវឱ្យមានចំនួនមនុស្សបីនាក់យ៉ាងតិច ពីព្រោះមនុស្សតែ ពីរនាក់ មិនអាចហៅថា ជាក្រុមមួយបានទេ (មាត្រា១១ នៃពង្រាងច្បាប់ស្តីពីសមាគម) ។ សំនួរថាតើច្បាប់អាចតម្រូវ

[៥១] សូមមើលវិបសាយ: www.hrni.org : (ចុចលើ "rights ans freedoms" បន្ទាប់មក ចុចលើ "freedom of reunion and association" ហើយបន្ទាប់មកទៀត ចុចលើ "specific instrument" )

ឱ្យគណបក្សនយោបាយ ឬសហជីពកម្មករត្រូវតែមានចំនួនសមាជិកលើសពី បីនាក់យ៉ាងតិចនោះ គឺជាបញ្ហាមួយនៃការដាក់កំហិតលើសិទ្ធិនៃការបង្កើតសមាគម (សូមមើលជំពូកបន្ទាប់) ។ ដោយសេរីភាពនៃការបង្កើតសមាគម គឺជាសិទ្ធិមនុស្សមួយដែលមនុស្សម្នាក់ៗត្រូវបានទទួលនោះ ( មាត្រា ២០ I UDHR និង មាត្រា ២២ I ICCPR) សមាគមជនបរទេសមួយ ក៏អាចទាមទារនូវការការពារសិទ្ធិនេះបានផងដែរ ។ ប្រសិនបើសិទ្ធិទទួលបានសេរីភាពនៃការបង្កើតសមាគមរបស់ពួកគេមិនត្រូវបានប្រគល់ឱ្យដោយរដ្ឋធម្មនុញ្ញ ( មាត្រា ៤២ I ១ CC ដែលសំដៅចំពោះតែ"ពលរដ្ឋខ្មែរ") យ៉ាងហោចណាស់សិទ្ធិនេះត្រូវតែប្រគល់ឱ្យ និងការពារដល់ជនបរទេសដោយច្បាប់សាមញ្ញណាមួយដែរ ។ ដូច្នេះ មាត្រា៣ I នៃពង្រាងច្បាប់ស្តីពីការបង្កើតសមាគម ត្រូវតែកែប្រែ ។

- ដែលចូលរួមជាមួយគ្នា**ដោយស្ម័គ្រចិត្ត**

- ដើម្បីសម្រេចបាននូវ**គោលបំណងរួមមួយ**ទោះជាអ្វីក៏ដោយ

គោលបំណងនីមួយៗត្រូវទទួលបានការការពារ ។ ពុំមានព្រំដែនចំពោះគោលបំណងណាមួយទេ ។ ( មាត្រា២០ នៃពង្រាងច្បាប់ស្តីពីការបង្កើតសមាគម ដែលរៀបរាប់ពីគោលបំណងផ្សេងៗ គ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ ប៉ុន្តែមិនមែនជាការអធិប្បាយដែលមិនប្រែប្រួលនោះទេ) ។ សំនួរសួរថា តើគោលបំណងឧក្រិដ្ឋកម្មមួយចំនួន (ដូចជា គោលបំណងប្រកាន់ពូជសាសន៍ ឬនិយមបំបែកខ្លួន) អាចត្រូវបានច្បាប់បដិសេធដែរឬក៏អត់? នេះគឺជាបញ្ហាមួយនៃការដាក់កំហិត ( សូមមើលជំពូកបន្ទាប់) ។

- សំរាប់ **រយៈពេលថិតស្ថេរ**កំណត់ណាមួយ

ការបង្កើតក្រុមមួយដោយឯកឯងភ្លាមៗនោះមិនទាន់គ្រប់គ្រាន់ទេ ។ មនុស្សដែលប្រមូលផ្តុំគ្នា ដើម្បីជួយគ្នាដោយឯកឯងភ្លាមៗបន្ទាប់ពីមានឧប្បត្តិហេតុមួយកើតឡើងនោះ មិនអាចហៅថាជាសមាគមមួយបានទេ ។ គោលបំណងរួមរបស់ពួកគេ មានក៏រិតត្រឹមតែរយៈពេលខ្លីមួយនៃសកម្មភាពបន្ទាន់ជាក់ស្តែងតែប៉ុណ្ណោះ ។

- នៅក្នុង **រចនាសម្ព័ន្ធចាត់តាំងមួយ** នៃការបង្កើតឆន្ទៈរួមមួយ

ដោយសមាគមមួយ ត្រូវការមានសមត្ថភាពធ្វើសកម្មភាពជាអ្នកតំណាងមួយសំរាប់សមាជិកទាំងអស់របស់ខ្លួននោះ វាត្រូវការនូវរចនាសម្ព័ន្ធចាត់តាំងមួយយ៉ាងតិច ។ ប៉ុន្តែ វាគ្រប់គ្រាន់ហើយ ប្រសិនបើមានមនុស្សណាម្នាក់ដែលត្រូវបានជ្រើសរើស ដែលអាចចុះហត្ថលេខាជួសមុខឱ្យ ឬតាងនាមឱ្យសមាគម (ដូច្នេះហើយមាត្រា១២ នៃពង្រាងច្បាប់ស្តីពីសមាគម ដែលតម្រូវឱ្យមានមនុស្សច្រើនជាងម្នាក់ ដូចជា នាយក ប្រធានក្រុមប្រឹក្សាភិបាល ហិរញ្ញិក ។ល ។ មិនត្រូវបានលើកឡើងដោយរដ្ឋធម្មនុញ្ញកម្ពុជាទេ មាត្រា ៤២ I ១ CC) ។

## ២. តើពាក្យថា **“សេរីភាព”** នៃការបង្កើតសមាគមមានន័យដូចម្តេច?

សេរីភាពនៃការបង្កើតសមាគមមានន័យថា ពុំមានការជ្រៀតជ្រែករបស់រដ្ឋ[៥២] ចូលក្នុងកិច្ចការរបស់សមាគម[៥៣] ឡើយ ។

ពិតហើយ បទបញ្ញារបស់រដ្ឋមួយចំនួនមានភាពចាំបាច់ដើម្បីផ្តល់ឱ្យ និងធានាថា សមាគមមួយមានបុគ្គលភាពគតិយុត្តិដោយខ្លួនឯង ដើម្បីឱ្យសមាជិករបស់សមាគម អាចធ្វើសកម្មភាពជាធ្លុងមួយប្រកបដោយប្រសិទ្ធភាពទៅខាងក្រៅ ។ ប្រសិនបើមានបទបញ្ញារដ្ឋបែបនេះពាក់ព័ន្ធនឹងការបង្កើតការចុះឈ្មោះ និងប្រតិបត្តិការរបស់សមាគមនោះ បទបញ្ញាទាំងនេះត្រូវតែធ្វើឡើងដើម្បីផ្តល់ឱ្យ និងធានានូវសេរីភាពនេះ មិនត្រូវធ្វើឡើងដើម្បីរារាំងសមាគមឡើយ ។ មាត្រា២ I ICCPR បានចែងច្បាស់ថា រដ្ឋ"ត្រូវតែធានាសិទ្ធិដែលមានចែងនៅក្នុងកតិកាសញ្ញានេះ ដល់បុគ្គលគ្រប់រូបនៅក្នុងដែនដីរបស់ខ្លួន" ។ នេះមានន័យថា រដ្ឋមានករណីយកិច្ចវិជ្ជមានដើម្បីផ្តល់ក្របខ័ណ្ឌនីយតកម្ម និងច្បាប់មួយ ដែលអនុញ្ញាតឱ្យបុគ្គលគ្រប់រូបដែលមានបំណងធ្វើការរួមគ្នាតាមរូបភាពដែលមានការទទួលស្គាល់តាមផ្លូវច្បាប់មួយ ដើម្បីធ្វើតាម ឆន្ទៈរបស់ខ្លួនបាន ។ ប្រសិនបើរដ្ឋធ្វើដូច្នោះបានហើយបង្កើតច្បាប់ទាំងឡាយ ដែលអនុញ្ញាតឱ្យ អង្គការមិនមែនរដ្ឋាភិបាលបានទទួលស្ថានភាពផ្លូវច្បាប់មួយនោះ រដ្ឋមិនមែនផ្តល់ការអនុគ្រោះតាមឆន្ទានុសិទ្ធិរបស់ខ្លួនទេ ក៏ប៉ុន្តែរដ្ឋគ្រាន់តែបំពេញករណីយកិច្ចរបស់ខ្លួនប៉ុណ្ណោះ ។

### ២.១. និយាយឱ្យពិស្តារ សេរីភាពនៃការបង្កើតសមាគមរួមមាន **សិទ្ធិរបស់បុគ្គលគ្រប់រូបដើម្បី :**

- ធ្វើការសម្រេចចិត្តរួមគ្នាដោយសេរី ដើម្បី**បង្កើត**សមាគមមួយសំរាប់គោលបំណង[៥៤] ណាមួយ

សេរីភាពនេះរួមមាន សិទ្ធិដើម្បីជ្រើសរើសឈ្មោះដោយសេរីសំរាប់សមាគមមួយ ។ ជួនកាលប្រការនេះបង្កឱ្យមានបញ្ហា ដោយអាជ្ញាធរព្យាយាមបង្កើតឧបសគ្គរារាំងដល់ការបង្កើតសមាគមមួយ ដោយអះអាងថា ឈ្មោះដែលត្រូវបានជ្រើសរើសនេះមានគេប្រើហើយ ឬអាចងាយមានការភ័ន្តច្រឡំជាមួយឈ្មោះដទៃទៀត ។

ឧទាហរណ៍ :

អាជ្ញាធរកម្ពុជាបានរំលាយគណៈបក្សនយោបាយមួយ ចំនួនបីដង ដោយអះអាងថា ឈ្មោះរបស់គណៈបក្សនេះដែលតែងតែផ្លាស់ប្តូរឡើងវិញជារៀងរាល់ដងនោះ មិនត្រឹមត្រូវទេ (មាត្រា១១ នៃច្បាប់ស្តីពីគណៈបក្សនយោបាយ) រហូតដល់គណៈបក្សនេះបង្កើតជាលើកចុងក្រោយ ដោយយកតាមឈ្មោះអ្នកដឹកនាំរបស់ខ្លួន (គណៈបក្សសមរង្ស៊ី) ។ នៅក្នុងករណីមួយទៀត គណៈមេធាវីបានអះអាងថា ឈ្មោះរបស់"សមាគមអ្នកការពារក្តីកម្ពុជា" ដែលទើបតែបង្កើតថ្មី អាចបង្កការភ័ន្តច្រឡំជាមួយឈ្មោះរបស់គណៈមេធាវី ។ ដោយមើលឃើញ បញ្ហានេះ មាត្រា១១ ចំនុចទី៣ នៃច្បាប់ស្តីពីគណៈបក្សនយោបាយ ហាក់ដូចជាមានភាពមិនច្បាស់ និងមិនស្របតាមរដ្ឋធម្មនុញ្ញ ។ មាត្រានេះបង្គាមិនឱ្យប្រើប្រាស់អត្តសញ្ញាណជាតិ ទោះជាអ្វីក៏ដោយ (ទង់ជាតិផងដែរ?) ហើយថែមទាំងរារាំងគណៈបក្ស

---

[៥២] សូមមើលឧទាហរណ៍មាត្រា៣ Nr. ២ អនុសញ្ញា ILO ស្តីពីសមាគមសេរីៈ "អាជ្ញាធរសាធារណៈមិនត្រូវធ្វើការជ្រៀតជ្រែកដែលអាចដាក់កំរិតលើសិទ្ធិនេះ ឬរារាំងដល់ការប្រើសិទ្ធិនេះ" ។

[៥៣] មតិយោបល់ដូចតទៅនេះស្តីអំពីសិទ្ធិផ្អែកលើ និក្ខេបបទរបស់មេធាវីនៃគណៈកម្មាធិការសិទ្ធិមនុស្សៈ "សិទ្ធិដែលគេមិនអើពើៈ សេរីភាពនៃការបង្កើតសមាគមនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ" ដែលយើងខ្ញុំស្នើសុំដោយទទូចសូមឱ្យលោក-អ្នក អានបន្ថែម ។
សូមមើល www.lchr.org/pubs/descriptions/neglrt.htm

ចំពោះ យុត្តិសាស្ត្រ និងសេចក្តីសម្រេច និងអនុសញ្ញាអន្តរជាតិ ដែលទាក់ទងទៅនឹងសេរីភាពនេះ សូមមើលនៅគេហទំព័រ HRNi ដែលមានឈ្មោះថា"rights and freedoms" នៅត្រង់ "freedom of reuion and association" សូមមើល www.hrni.org

ជាចុងក្រោយ លោក-អ្នក ឃើញគណៈកម្មការសិទ្ធិមនុស្សទាំងអស់ ដែលបញ្ចប់ការសង្កេតការណ៍ និងយុត្តាធិការគណៈកម្មាធិការសិទ្ធិមនុស្សស្តីពីការគោរពសេរីភាពនៃការបង្កើតសមាគម នៅក្នុងរដ្ឋផ្សេងៗ នៅក្នុងពិភពលោក ក្នុងរយៈពេល១០ ឆ្នាំកន្លងមកនៅគេហទំព័រ bayefsky សូមមើលwww.bayefsky.com (សូមចុចលើ "Document by Theme and Subject Matter") ហើយបន្ទាប់មក សូមចុចលើ "association-freedom of")

[៥៤] សូមមើលមាត្រា២ នៃអនុសញ្ញា ILO ស្តីពីសមាគមដោយសេរី : "កម្មករមានសិទ្ធិបង្កើតអង្គការតាមជំរើសផ្ទាល់ខ្លួនរបស់គេ" ។

រាជានិយម មិនឱ្យប្រើនិមិត្តសញ្ញាព្រះរាជាណាមួយទៀតផង ។ ប៉ុន្តែ ពុំមានហេតុផលណាមួយគួរឱ្យជឿបញ្ហានេះឡើយ ។

- **រំលាយ** សមាគមដោយសេរី ដោយសេចក្ដីសម្រេចចិត្តរួមសំរាប់ហេតុផលណាមួយ

សិទ្ធិនៃការរំលាយខ្លួនឯងស្របតាមលក្ខន្តិកៈរបស់សមាគមត្រូវបានគេផ្ដល់ឱ្យ មាត្រា៣៣ ឃ្លាទី១ នៃច្បាប់ស្ដីពីគណៈបក្សនយោបាយ និង មាត្រា១៦ ចំណុចទី១ នៃពង្រាងច្បាប់ស្ដីពីការបង្កើតសមាគម ។ ក៏ប៉ុន្តែសមាគមមួយ ជាទូទៅមិនត្រូវបានរំលាយ ឬព្យួរការងារដោយអំណាច រដ្ឋបាលណាមួយឡើយ ប៉ុន្តែ អាចរំលាយបានដោយមានសេចក្ដីសម្រេចចិត្តរួមពីសមាជិករបស់ ខ្លួនតែប៉ុណ្ណោះ (សូមមើលមាត្រា៤ អនុសញ្ញា ILO ស្ដីពីសេរីភាពនៃការបង្កើតសមាគម) ។ នៅក្នុងករណីលើកលែងមួយចំនួន ការរំលាយអាចធ្វើឡើងដោយសេចក្ដីបង្គាប់ពីតុលាការបាន (ឧទាហរណ៍ មាត្រា៣៤ នៃច្បាប់ស្ដីពីគណៈបក្សនយោបាយៈ ការរំលាយដោយសេចក្ដីបង្គាប់របស់តុលាការអាចធ្វើបានតែក្នុងករណីក្ស័យធនប៉ុណ្ណោះ) ។ តាមទស្សនៈនៃមាត្រា១៦ ចំណុចទី២ និង ៣ នៃពង្រាងច្បាប់ស្ដីពីការបង្កើតសមាគម មានលក្ខណៈហួសព្រំដែនបន្តិចហើយ ដោយអនុញ្ញាតឱ្យមានការរំលាយបែបរដ្ឋបាលក្រោមលក្ខខណ្ឌដែលពុំមានន័យច្បាស់លាស់ ។

- **ចូលរួមជាមួយសមាគមណាមួយដែលមានស្រាប់បានដោយសេរី**

ការអនុវត្តន៍សិទ្ធិក្នុងការចូលជាសមាជិកនៃសមាគមមួយ អាចមានលក្ខណៈសេរីទៅបាន លុះត្រាតែការអនុវត្តន៍សិទ្ធិនេះ ត្រូវធ្វើឡើងដោយស្ម័គ្រចិត្តដោយគ្មានការបង្ខិតបង្ខំ ។ ដូច្នេះ ប្រការនេះក៏ផ្ដល់សិទ្ធិឱ្យបុគ្គលគ្រប់រូបធ្វើការបដិសេធសមាជិកភាពរបស់ខ្លួន នៅក្នុងអង្គការណា មួយដែលគេមិនចូលចិត្តបានដែរ ។

សូមមើលផងដែរនូវ មាត្រា២០ I UDHRៈ "គ្មាននរណាម្នាក់ត្រូវបានគេបង្ខំឱ្យចូលជាសមាជិកនៃសមាគមណាមួយឡើយ" ។

សូមមើលបន្ថែមនូវមាត្រា៥ I ២ នៃច្បាប់ស្ដីពីគណៈបក្សនយោបាយៈ "គ្មានបុគ្គលណាម្នាក់ អាចមានសិទ្ធិបង្ខំនរណាម្នាក់ឱ្យចូលជាសមាជិកគណៈបក្សនយោបាយណាមួយនោះទេ ។

(សូមមើលផងដែរនូវមាត្រា២៧៣ នៃច្បាប់ការងារ)

- **ចូលជាសមាជិក**នៃសមាគមណាមួយដោយសេរី

សេរីភាពនេះរាប់បញ្ចូលសិទ្ធិទទួលបានការការពារពីការគំរាមកំហែង ឬការធ្វើទុកបុកម្នេញ ដោយផ្ទាល់ ឬដោយប្រយោលពីសំណាក់រដ្ឋ ឬបុគ្គលផ្សេងទៀត ដែលមានបំណងធ្វើបាបជនណាម្នាក់ដោយសារសមាជិកភាពរបស់គេ ហើយព្យាយាមធ្វើឱ្យគេបោះបង់សមាជិកភាពនោះ ។

មាត្រា៥ II នៃច្បាប់ស្ដីពីគណបក្សនយោបាយៈ "ពុំមាននរណាម្នាក់ត្រូវបានគេដកហូតសិទ្ធិពលរដ្ឋ នយោបាយ វិជ្ជាជីវៈ ដោយសារតែបុគ្គលនោះជា ឬមិនមែនជាសមាជិកនៃគណបក្សដែល មានមូលដ្ឋានច្បាប់ត្រឹមត្រូវឡើយ" ។

សូមមើលមាត្រា២៧៩ និង ២៨០ នៃច្បាប់ការងារ ដែលការពារសមាជិកសហជីពពីគុណវិបត្តិវិជ្ជាជីវៈដោយសារសមាជិកភាពរបស់ពួកគេ ។

- **ចាកចេញពីសមាគមណាមួយដោយសេរី**

ដោយគ្មាននរណាម្នាក់ ត្រូវបានគេបង្ខំឱ្យចូលរួមជាមួយសមាគមណាមួយនោះ ក៏ពុំត្រូវមានការបង្ខំដើម្បីរក្សាបុគ្គលណាម្នាក់នៅក្នុងសមាគមជាសមាជិកដែរ ។ បើមិនដូច្នោះទេ សមាជិកភាពរបស់គេលែងពឹងផ្អែកលើការសម្រេចចិត្តដោយសេរីរបស់គេតទៅទៀតឡើយ ។

ឧទាហរណ៍:
សមាគម "ក្មេងវត្ត" បានបង្ខំសមាជិកមួយចំនួនរបស់ខ្លួន ដោយធ្វើការបំភិតបំភ័យ និងការរំលោភ លើរាងកាយ ដើម្បីឱ្យពួកគេនៅធ្វើជាសមាជិកតទៅទៀត ទោះបីជាមនុស្សទាំងនេះបានលាឈប់ ជាសាធារណៈពីអង្គការនេះ ហើយក៏ដោយ (សូមមើលអត្ថបទនៅក្នុងកាសែត "ឌឹរខាំបូឌាដេលី" ចុះផ្សាយថ្ងៃទី១០ មិថុនា ២០០៣ ទំព័រទី១ ជាពិសេសទំព័រទី២) ។ អាកប្បកិរិយាបែបនេះ មិនត្រូវបានការពារដោយសេរីភាពនៃការបង្កើតសមាគមឡើយ ។

សូមមើលបន្ថែមត្រង់មាត្រា២៧៣ នៃច្បាប់ការងារ ដែលការពារសេរីភាពក្នុងការដកខ្លួន ចេញពីសហជីព "នៅពេលណាមួយ" ។ ការលាលែងដោយសេរីអាចមានលក្ខណៈ "សេរី" ពិតប្រាកដទៅបាន លុះត្រាតែបុគ្គលម្នាក់អាចលាលែងដោយមិនចាំបាច់ផ្តល់ហេតុផលណាមួយ (សូមមើលមាត្រា១៣ ឃ្លាទី២ នៃច្បាប់ស្តីពីគណបក្សនយោបាយ) ។

**២.២. សមាគមផ្ទាល់មានសិទ្ធិ :**

**ទទួលបានបុគ្គលភាពគតិយុត្តិមួយដោយ** មានលក្ខខណ្ឌដែលមិនអត្តនោម័ត ឬដែលត្រឹមត្រូវ ។ សិទ្ធិនេះរាប់បញ្ចូលទាំងសិទ្ធិចុះឈ្មោះនៅក្នុង **ដំណើរការចុះឈ្មោះមួយដែល :**

- រហ័ស
- ត្រង់
- ចំណាយប្រាក់តិច និង
- ស្ថិតក្រោមការពិនិត្យរបស់តុលាការ

ដើម្បី **ប្រព្រឹត្តិទៅដោយសេរី** ដោយការជ្រៀតជ្រែកពីរដ្ឋ ដែលរួមមានសិទ្ធិដើម្បី :

- **ស្វែងរកការគាំទ្រហិរញ្ញវត្ថុ** ដោយសេរី (ព្រមទាំងប្រភពនៅក្រៅប្រទេសផង)
- **ចូលរួមដោយសេរីជាមួយអង្គការផ្សេងទៀត**(ព្រមទាំងអង្គការអន្តរជាតិផង)
- **បញ្ញត្តិសំរាប់កិច្ចការរបស់ខ្លួន** បង្កើតឬកែប្រែបទបញ្ជាផ្ទៃក្នុង និង
- **ធ្វើកូដកម្មមិនព្រមចូលធ្វើការ** (នៅពេលដែលសមាគម គឺជាសហជីពកម្មករ)

ចំណុចខាងលើនេះមានន័យពិស្តារដូចតទៅ :

**ក. សិទ្ធិទទួលបានបុគ្គលភាពគតិយុត្តិ :**

បុគ្គលភាពគតិយុត្តិមានសារៈសំខាន់សំរាប់ដំណើរការប្រកបដោយប្រសិទ្ធភាពរបស់មនុស្សមួយក្រុម ដែលមានបំណងធ្វើជាសមាគមមួយ ។ បុគ្គលភាពនេះអាចធ្វើឱ្យសមាគមមានលទ្ធភាពបើក គណនីធនាគារ ជួល និងបណ្តេញបុគ្គលិក ជួលផ្ទះ និងផ្តល់សិទ្ធិដល់សមាគមដើម្បីនាំរឿងក្តីឡើង តុលាការ ។

ដោយសិទ្ធិទទួលបានសេរីភាពនៃការបង្កើតសមាគមជាសិទ្ធិពីកំណើតនោះ ការផ្តល់បុគ្គលភាពគតិយុត្តិមិនមែនគ្រាន់តែជាការអនុគ្រោះ ដែលរដ្ឋាភិបាលអាច ឬមិនអាចផ្តល់ឱ្យ ជាថ្នូរនឹងអាកប្បកិរិយារបស់សមាគម ជាមិត្តភាព ឬមិនរិះគន់តែប៉ុណ្ណោះទេ ។ ក៏ប៉ុន្តែ វាជាករណីយកិច្ចមួយក្នុងការផ្តល់ស្ថានភាពបែបនេះ ដរាបណាលក្ខខណ្ឌ

អប្បបរមាមួយចំនួនត្រូវបានបំពេញ ដែលលក្ខខណ្ឌទាំងនេះអាចឱ្យសមាគមធ្វើសកម្មភាពក្នុងនាមជានីតិបុគ្គលមួយ ។ ករណីកិច្ចនេះរួមមាន ការទទួលខុសត្រូវច្បាស់លាស់ និងការផ្តល់សិទ្ធិដល់សមាជិកតំណាងរបស់ខ្លួន ព្រមទាំងការធានារ៉ាប់រងច្បាស់លាស់ផងដែរ ។ ដូច្នេះ ពុំមានការព្រួយបារម្ភចំពោះលក្ខខណ្ឌទាំងនោះទេ ដរាបណាលក្ខខណ្ឌទាំងនេះស្វែងយល់ពីគោលបំណងនោះ ដើម្បីធ្វើឱ្យប្រាកដថា សមាគមមានរចនាសម្ព័ន្ធ និងបទបញ្ជាបែបនេះ ហើយគ្មាននរណាម្នាក់អាចប្រើសមាគមនេះ ដើម្បីគេចវេសពីការបង់ពន្ធ ឬដើម្បីជៀសវាងពីការធានារ៉ាប់រង ឬការទទួលខុសត្រូវចំពោះសកម្មភាពដែលត្រូវបានធ្វើឡើងក្នុងនាម សមាគមឡើយ ។

ខ. ដំណើរការចុះឈ្មោះសមស្រប :

កក. ការចុះឈ្មោះ គឺជាលក្ខខណ្ឌចាំបាច់មួយសំរាប់ការទទួលបានបុគ្គលភាពគតិយុត្តិ ។ ប៉ុន្តែការចុះឈ្មោះនេះ ត្រូវតែធ្វើឡើងដោយការស្ម័គ្រចិត្តជានិច្ច ។ ការចុះឈ្មោះដោយបង្ខំអាចរំលោភលើសេរីភាពនៃការបង្កើតសមាគម ពីព្រោះវាបើកទ្វារសំរាប់ការត្រួតពិនិត្យ និងការជំទាស់របស់រដ្ឋាភិបាល ។ ដូច្នេះ បើសិនណាពួកគេស្ម័គ្រចិត្តជ្រើសរើសចង់បានបុគ្គលភាពគតិយុត្តិ ពួកគេគឺជាកម្មវត្ថុនៃការចុះឈ្មោះជាជម្រើស ( មិនបង្ខិតបង្ខំ) ។ (សូមមើលមាត្រា៦ ពង្រាងច្បាប់ស្តីពីការបង្កើតសមាគម ដែលគូសបញ្ជាក់យ៉ាងច្បាស់ថាៈ "ដើម្បីឱ្យសមាគមមួយអាចទទួលបាននូវបុគ្គលភាពគតិយុត្តិ អ្នកបង្កើតត្រូវរៀបចំឯកសារដាក់ពាក្យសុំចុះឈ្មោះ") ។

ខខ. ការចុះឈ្មោះ ត្រូវតែធ្វើឱ្យបានរហ័ស នេះមានន័យថា ការចុះឈ្មោះមិនត្រូវពន្យាពេលឱ្យហួសកាលកំណត់ឡើយ ។

ឧទាហរណ៍ៈ ដើម្បីធ្វើឱ្យការចុះឈ្មោះបានលឿន មាត្រា៨ ឃ្លាទី៣ នៃពង្រាងច្បាប់ស្តីពីការបង្កើតសមាគមកំណត់ថា សមាគមមួយត្រូវបានចាត់ទុកថាមានបុគ្គលភាពគតិយុត្តិជាសមាគមមួយដែលបានចុះបញ្ជីត្រឹមត្រូវ ប្រសិនបើក្រសួងខកខានមិនបានឆ្លើយតបក្នុងរយៈពេល ៤៥ម៉ោង បន្ទាប់ពីការដាក់ ពាក្យសុំចុះឈ្មោះ ។

គគ. ការចុះឈ្មោះ មានន័យថា ការជូនដំណឹងដល់អាជ្ញាធរ និងការបំពេញលក្ខខណ្ឌមូលដ្ឋានមួយចំនួន ។ ប្រការនេះត្រូវធ្វើឡើងដោយគ្មានកង្វល់អ្វីឡើយ ។

ប៉ុន្តែសូមចងចាំថា : វិធានជាមូលដ្ឋាន គឺថា លក្ខខណ្ឌគួរតែកំណត់ឱ្យបានតិចបំផុត!

(១) តើច្បាប់អាចតម្រូវឱ្យមានចំនួនសមាជិកតិចបំផុតដែរ ឬទេ?

ត្រឹមត្រូវហើយ ។ ក៏ប៉ុន្តែ បានតែក្នុងករណីដែលវាស្វែងយល់ពីគោលបំណងស្របច្បាប់ ដើម្បីធានា អត្ថិភាពដែលអាចស្ថិតស្ថេរបាន និងសមហេតុផលនៃសមាគមតែប៉ុណ្ណោះ ។ ច្បាប់មួយអាចនឹងអធម្មនុញ្ញភាព ប្រសិនបើច្បាប់នោះរារាំងសមាគមតូចតាច មិនឱ្យចុះឈ្មោះដោយសារសមាគមនោះតូចតាច :

ឧទាហរណ៍ៈ

វាអាចមិនមានបញ្ហាអ្វីទេ ក្នុងការតម្រូវឱ្យមានសមាជិកស្ថាបនិកចំនួន បីរូប ប៉ុន្តែវាមិនមែនជារឿងត្រឹមត្រូវតាមច្បាប់ឡើយក្នុងការតម្រូវថា សមាគមមួយត្រូវតែមានប្រធានហិរញ្ញិកជាដើម (មាត្រា១១ និង១២ នៃពង្រាងច្បាប់ស្តីពីការបង្កើតសមាគម) ។ ដោយគណបក្សនយោបាយនានា មានបំណងចូលរួមក្នុងការបោះឆ្នោតជាតិ និងមានបំណងអនុវត្តអំណាច ប្រសិនបើពួកគេបានឈ្នះឆ្នោត នោះការតម្រូវឱ្យមានសមាជិកចំនួន ៤.០០០នាក់ សំរាប់ការចុះឈ្មោះនោះលែងមានអ្វីគួរឱ្យព្រួយបារម្ភទៀតហើយ (មាត្រា១៩ I នៃច្បាប់ស្តីពីគណបក្សនយោបាយ ដែលហាក់ដូចជាមិនស៊ីសង្វាក់គ្នា ជាមួយមាត្រា៩ I នៃច្បាប់នេះសោះ) ។ ប៉ុន្តែ ការតម្រូវឱ្យសមាជិកទាំង ៤.០០០នាក់

មកពីខេត្ត ផ្សេងៗមួយចំនួនពុំមានគោលដៅច្បាស់លាស់សោះ ។ ហេតុដូចម្ដេចបានជាវាមិនអាចធ្វើទៅបានដើម្បីមានគណបក្សមួយដែលគ្រាន់តែមានបំណងតំណាងតំបន់មួយនោះ?

(២) តើច្បាប់អាចត្រូវការពតិមានស្ដីពីសេចក្ដីលំអិតផ្ទៃក្នុងរបស់សមាគម ដែរឬទេ?

មែនហើយ ពីព្រោះពតិមានខ្លះមិនអាចជៀសវាងបានឡើយសំរាប់គោលដៅនៃការចុះឈ្មោះ ។

ករណីយកិច្ចត្រូវផ្ដល់ឈ្មោះ និងអាស័យដ្ឋានទំនាក់ទំនងរបស់អ្នកទទួលខុសត្រូវដែលតំណាងឱ្យសមាគម និងដើម្បីប្រាប់ពីគោលបំណង និងអាស័យដ្ឋាន ព្រមទាំងលក្ខន្តិក: ហើយវចនាសម្ព័ន្ធសមាគម គឺជាមូលដ្ឋាន និងចាំបាច់ ។ មាត្រា២៦៨ នៃច្បាប់ការងារ គឺជាឧទាហរណ៍ដ៏ល្អមួយសំរាប់ការកំណត់នៃការចុះឈ្មោះដែលមានភាពធូរស្រាល និងសេរី ដែលគ្រាន់តែត្រូវការពតិមានដែលចាំបាច់ បំផុតសំរាប់ការចុះឈ្មោះរបស់សហជីពកម្មករមួយ ។

ប៉ុន្ដែ វាជាការមិនចាំបាច់ទេ ដែលរដ្ឋដឹងគ្រប់សេចក្ដីផ្ទៃក្នុងទាំងអស់របស់សមាគមមួយ ដូចជា ការទទួលរបាយការណ៍ប្រចាំឆ្នាំ ឈ្មោះសមាជិក ឬឯកសារបញ្ជីលំអិតស្ដីពីទ្រព្យទាំងអស់ និងប្រវត្តិហិរញ្ញវត្ថុ ឬប្រវត្តិរូបរបស់អ្នកដឹកនាំ ។ ការធ្វើដូច្នេះ អាចបើកទ្វារឱ្យរដ្ឋាភិបាលបានធ្វើការត្រួតពិនិត្យដែលមានលក្ខណ:ហួសព្រំដែនបន្ដិច និងដែលមិនសមាមាត្រ ។ នេះគឺជាវិធានការមួយទន់ភ្លន់ដែលត្រូវធ្វើបន្ទាប់ពីសមាគមមួយធ្វើសកម្មភាពខុសច្បាប់តែប៉ុណ្ណោះ ។ អាជ្ញាធរអាចចាត់វិធានការខ្លាំងហួសហេតុ ប្រសិនបើពួកគេដាក់កំរិតលើសមាគមមួយមុនពេលសមាគមនោះធ្វើសកម្មភាព ។ ការទាមទារឈ្មោះ និងអាស័យដ្ឋានរបស់សមាជិកសមាគម អាចធ្វើឱ្យពួកគេងាយទទួលរងនូវការគំរាមកំហែង និងការបំភិតបំភ័យ ។

ឧទាហរណ៍:

តាមទស្សនៈមាត្រា៦ និង១៤ នៃពង្រាងច្បាប់ស្ដីពីការបង្កើតសមាគម និងមាត្រា២០ ចំនុច១-៧ នៃច្បាប់ស្ដីពីគណបក្សនយោបាយហាក់ដូចជាគ្មានបញ្ហាព្រួយបារម្ភអ្វីទេ ។ ប៉ុន្ដែ មាត្រា២០ ចំនុច៨-១១ នៃច្បាប់ស្ដីពីគណបក្សនយោបាយហាក់ដូចជាមានលក្ខណៈជ្រុលបន្ដិច ពីព្រោះ ពតិមានទាំងនេះហាក់ដូចជាមិនចាំបាច់សោះ ។

ដូចគ្នាដែរ ករណីយកិច្ចលំអិតក្នុងការលាតត្រដាង សកម្មភាពទាំងអស់ កិច្ចការហិរញ្ញវត្ថុ របាយការណ៍ប្រចាំឆ្នាំ ហាក់ដូចជាមិនចាំបាច់ដល់កំរិតនេះទេ ទោះបីជាអាចមានហេតុផលមួយចំនួន ដើម្បីទទួលបានកំរិតនៃតម្លាភាពមួយជាពិសេសសំរាប់គណបក្ស និងអង្គការក្រៅរដ្ឋាភិបាល ដែលមានតួនាទីដ៏មានឥទ្ធិពលនៅក្នុងជីវិតសាធារណ: ដោយពុំចាំបាច់មានការបោះឆ្នោតជ្រើសតាំងក៏ដោយ ។

ករណីយកិច្ចចំពោះពតិមានដ៏ទូលំទូលាយនៅក្នុងមាត្រា ១៨, ២១, ២២ និង២៧ នៃពង្រាងច្បាប់ស្ដីពីការបង្កើតសមាគម ឬនៅក្នុងមាត្រា៣១ នៃច្បាប់ស្ដីពីគណបក្សនយោបាយ អាចរារាំងប្រជាជនមិនឱ្យចុះឈ្មោះសមាគមរបស់គេរួចទៅហើយ ពីព្រោះដើម្បីបំពេញករណីយកិច្ចទាំងនេះទាមទារនូវកម្លាំងការងារ និងជំនាញផ្នែករៀបចំជាច្រើន និងការបញ្ចេញពតិមានសំងាត់អំពីកិច្ចការផ្ទៃក្នុងដល់សាធារណជន (ដូចជា ប្រាក់បៀវត្សនៃប្រវត្តិរូបសង្ខេបនៃបុគ្គលិកសមាគមជាដើម) ។

ឧទាហរណ៍:

តុលាការកំពូលអាមេរិចបានសម្រេចថា ករណីយកិច្ចដែលតម្រូវឱ្យ សមាគមសិទ្ធិពលរដ្ឋរបស់ជនជាតិអាមេរិចស្បែកខ្មៅ ចុះបញ្ជីឈ្មោះ អាស័យដ្ឋានរបស់សមាជិក និងឯកសារហិរញ្ញវត្ថុទាំងអស់ នឹងបង្កគ្រោះថ្នាក់ធំធេងនៃការបៀតបៀនដល់សមាជិក និងការបាត់បង់ប្រសិទ្ធិភាព[៥៥] របស់អង្គការ ។

[៥៥] សូមមើល NAACP v.Alabama ៣៥៧US ៤៤៩ (១៩៥៨) សូមមើលករណីនេះនៅក្នុងវិបសាយ : www.lchr.org/pubs/descriptions/neglrt.htm ។

(៣) តើច្បាប់គួរតម្រូវឱ្យមានការត្រួតពិនិត្យរបស់តុលាការលើការបដិសេធន៍ចំពោះការដាក់ពាក្យសុំចុះឈ្មោះដែរឬទេ?

បាទ/ចាស ។ សេចក្ដីសម្រេចផ្នែករដ្ឋបាលណាមួយ ដូចគ្នានឹងដំណើរការចុះឈ្មោះដែរ ត្រូវតែស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ ។ បើមិនដូច្នោះទេ រដ្ឋាភិបាលអាចបញ្ឈប់សមាគមទាំងអស់ មិនឱ្យបង្កើតឡើងបានដោយគ្មានការពន្យល់ហេតុផលណាមួយបាន ។ គោលការណ៍នៃការត្រួតពិនិត្យ នេះត្រូវបានធានានៅក្នុងមាត្រា២៥នៃច្បាប់ស្ដីពីគណបក្សនយោបាយ ដែលចែងថា ភាគីមួយអាចដាក់ពាក្យបណ្ដឹងជំទាស់នឹងការបដិសេធន៍ចំពោះការចុះឈ្មោះទៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលក្រុមប្រឹក្សានេះនឹងធ្វើការពិនិត្យសម្រេចក្នុងរយៈពេល ៣០ថ្ងៃ ។ (សូមមើលមាត្រា១០ នៃពង្រាងច្បាប់ស្ដីពីការបង្កើតសមាគមផង) ។

គ. សិទ្ធិដើម្បីដំណើរការប្រព្រឹត្តិទៅដោយសេរីដោយគ្មានការជ្រៀតជ្រែក មានន័យពិស្ដារ ដូចតទៅ :

• **ស្វែងរកការគាំទ្រផ្នែកហិរញ្ញវត្ថុ** ដោយសេរី (ព្រមទាំងប្រភពនៅក្រៅប្រទេសផង)

វាហាក់ដូចជាគ្មានហេតុផលគួរឱ្យជឿបានពិតប្រាកដសោះថា តើហេតុអ្វីបានជាការផ្ដល់ថវិកាពីបរទេសមិនត្រូវបានអនុញ្ញាត ។ តើការផ្ដល់ថវិកានេះធ្វើអោយខូចខាតអ្វីខ្លះដល់សមាគម? ចំពោះ អង្គការមិនមែនរដ្ឋាភិបាលភាគច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ការឧបត្ថម្ភបែបនេះមានសារៈសំខាន់បំផុត ។ ដូច្នេះហើយ មាត្រា២១ឃ្លាទី១ នៃពង្រាងច្បាប់ស្ដីពីការបង្កើតសមាគម ចែង យ៉ាងច្បាស់ថា ការផ្ដល់ថវិកាពីបរទេសគឺស្របច្បាប់ ។

ផ្ទុយពីនោះ មាត្រា២៧ ចំនុចទី៤ និង២៩ នៃច្បាប់ស្ដីគណៈបក្សនយោបាយ ហាមគណៈបក្សនយោបាយមិនឱ្យទទួលមូលនិធិពីម្ចាស់ជំនួយឯកជនបរទេស NGOs និង "ក្រុមហ៊ុនបរទេសផ្សេងៗ" ។ ភាពត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញនៃនិយតកម្មទូទៅនេះអាចធ្វើឱ្យសង្ស័យបាន ។ ដើម្បីធានានូវតម្លាភាព និងភាពទទួលខុសត្រូវនៃគណបក្សនយោបាយទាំងអស់ ច្បាប់ស្ដីពីគណបក្សនយោបាយអាចតម្រូវឱ្យមានការផ្ដន្ទាទោសដល់ជំនួយទាំងឡាយណាដែលមានចំនួនលើសពីចំនួនជាក់លាក់ណាមួយ (ឧទាហរណ៍ ៥.០០០ ដុល្លារអាមេរិច) ។

• **ការចូលរួមជាមួយអង្គការដទៃទៀតដោយសេរី** (ព្រមទាំងអង្គការអន្តរជាតិផង)

សេរីភាពនេះមានចែងយ៉ាងច្បាស់នៅក្នុងមាត្រា៥ អនុសញ្ញា ILO ស្ដីពីសេរីភាពនៃការបង្កើតសមាគម ដែលចែងថា អង្គការកម្មករ ឬនិយោជកមានសិទ្ធិដើម្បីបង្កើត និងចូលរួមក្នុងសហព័ន្ធ នៃអង្គការដទៃទៀតរាប់បញ្ចូលទាំងអង្គការអន្តរជាតិផង ។

• **ធ្វើនិយតកម្មលើកិច្ចការរបស់ខ្លួនផ្ទាល់** បង្កើត ឬកែប្រែបទបញ្ជាផ្ទៃក្នុង

មាត្រា៣ I អនុសញ្ញា ILO ស្ដីពីសេរីភាពនៃការបង្កើតសមាគមចែងយ៉ាងច្បាស់អំពីសេរីភាពនេះ ។ អនុសញ្ញានេះចែងថា អង្គការកម្មករ/និយោជកមានសិទ្ធិដើម្បីបង្កើតធម្មនុញ្ញ និងបទបញ្ជារបស់ពួកគេ ជ្រើសរើសតំណាងដោយមានសេរីភាពពេញលេញ និងរៀបចំរដ្ឋបាល និងសកម្មភាពផ្សេងៗរបស់ខ្លួន និងដើម្បីបង្កើតកម្មវិធីនានារបស់ខ្លួន ។ នេះគឺជាបញ្ជាក់អំពីសេរីភាពទូទៅនៃការបង្កើត សមាគម ដើម្បីគ្រប់គ្រងដោយខ្លួនឯង ។

ឧទាហរណ៍:

វាជាការរំលោភសេរីភាពនៃការគ្រប់គ្រងដោយខ្លួនឯងនេះ ប្រសិនបើ ច្បាប់មួយបង្កើតសិទ្ធិណាមួយសំរាប់ប្រជាពលរដ្ឋណាមួយដើម្បី "ចូលរួមសមាគមណាមួយ ប្រសិនបើគេយល់ព្រមនឹងគោលការណ៍របស់សមាគមនោះ" ។

ច្បាប់នេះត្រូវបានអនុម័តនៅក្នុងប្រទេសទុយនេស៊ី (Tunisia) ដើម្បីឱ្យរដ្ឋាភិបាល អាចបញ្ជូនសមាជិកនៃគណបក្សកាន់អំណាចទៅក្នុងសមាគមសិទ្ធិមនុស្ស ហើយទទួលបានសម្លេងភាគច្រើន ហើយបន្ទាប់មកបំផ្លាញសមាគមនេះពីខាងក្នុង ។

ម្យ៉ាងវិញទៀត រដ្ឋាភិបាលនីស៊េរីយ៉ា បានអនុម័តច្បាប់មួយដែលបានបង្កើតស្ថាប័នថ្មីមួយនៃគណៈមេធាវីដែលបានបញ្ចូលចំនួន ៣/៤ នៃបេក្ខជនរបស់រដ្ឋាភិបាល ។

ដូច្នេះ សមាគមណាមួយ ត្រូវតែមានសេរីភាពក្នុងការធ្វើសេចក្ដីសម្រេចចិត្តថា តើសមាជិករបស់ខ្លួនមានបំណងទទួលយកនរណាជា សមាជិកថ្មី ។

ឧទាហរណ៍:

វាហាក់ដូចជាមិនសមស្របទៅនឹងសេរីភាពនៃការគ្រប់គ្រងខ្លួនឯងឡើយ ដែលថា

- មាត្រា៣ នៃច្បាប់ស្ដីគណបក្សនយោបាយ កំណត់ថា គណបក្សនយោបាយកម្ពុជាទាំងអស់ ត្រូវដាក់ទីតាំងការិយាល័យធំរបស់ខ្លួននៅក្នុងទីក្រុងភ្នំពេញ ។ ហេតុអ្វីបានជាគេមិនអាចទុកសេចក្ដីសម្រេចនេះឱ្យសមាជិកគណបក្សជាអ្នកសម្រេចដោយផ្ទាល់នៅក្នុងលក្ខន្តិកៈរបស់ខ្លួន?)
- មាត្រា១៥ ឃ្លាទី១ នៃច្បាប់ស្ដីពីគណបក្សនយោបាយ ចែងថា គ្មាននរណាម្នាក់អាចធ្វើជា សមាជិកនៃគណបក្សពីរនៅពេលតំណាលគ្នាបានទេ ។ ហេតុអ្វីបានជាច្បាប់នេះមិន ទុកចំណុចនេះនៅក្នុងបទបញ្ជាផ្ទៃក្នុងនៃគណបក្សរបស់គេ?) គណបក្សដឹងច្បាស់នូវអ្វីដែលគេត្រូវធ្វើ ។ ប្រសិនបើពួកគេចង់ទទួលយកសមាជិកភាពពីរដងឧទាហរណ៍នៅក្នុងគណបក្សចំរុះ រឿងនេះស្រេចលើពួកគេជាអ្នកដោះស្រាយនូវផលវិបាកនេះ ។

- **ការអនុវត្តនីសកម្មភាពនានា ជាពិសេសសិទ្ធិធ្វើកូដកម្មមិនធ្វើការ** (នៅពេលសមាគមគឺជាសហជីពកម្មករ)

សេរីភាពនេះធានាថា សមាគមមួយអាចអាចអនុវត្តតាមគោលបំណង និងគោលដៅទាំងអស់របស់ខ្លួនបានដោយសេរី ដរាបណាពួកគេមិនរំលោភសិទ្ធិដទៃទៀតទេនោះ មាត្រា៣១ III CC ។

សិទ្ធិធ្វើកូដកម្មមិនធ្វើការ ត្រូវបានបញ្ចូល និងមានចែងជាពិសេសនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា (មាត្រា៣៧ CC សូមមើលបន្ថែមត្រង់មាត្រា៣១៩ I ១ នៃច្បាប់ការងារ) ។ សេរីភាពដើម្បីអនុវត្ត សកម្មភាពស្របច្បាប់ទាំងអស់រាប់បញ្ចូលសេរីភាពក្នុងការលើកផ្លាកគណបក្សនៃគណបក្ស ដូចជា នៅក្នុងបរិវេណសួនច្បារនៃគេហដ្ឋានរបស់សមាជិកគណបក្សណាម្នាក់ ដោយមិនចាំបាច់សុំការអនុញ្ញាតពីអាជ្ញាធរជាមុនឡើយ ។ (មាត្រា៩ III ច្បាប់ស្ដីពីគណបក្សនយោបាយ ថែមទាំងដឹងជាមុនថា សិទ្ធិនេះត្រូវបានផ្ដល់ឱ្យគណបក្សណាមួយរួចហើយក្នុងកំឡុងពេលនៃការចុះឈ្មោះរបស់ខ្លួននោះ ។ នៅពេលថ្មីៗនេះគណៈកម្មាធិការរៀបចំការបោះឆ្នោតជាតិ (NEC) បានចេញសេចក្ដីណែនាំរដ្ឋបាលដល់អាជ្ញាធររដ្ឋរបស់កម្ពុជាទាំងអស់ថា ប្រសិនបើនរណាម្នាក់ចង់លើកផ្លាកគណបក្ស គេពុំចាំបាច់ត្រូវការការអនុញ្ញាតឡើយ វៀរលែងតែគេលើកផ្លាកនៅលើផ្លូវសាធារណៈ ។ បញ្ហានេះមានសារៈសំខាន់ណាស់ពីព្រោះនៅក្នុងករណីជាច្រើន អាជ្ញាធរមូលដ្ឋាននៅក្នុងប្រទេសកម្ពុជាបានរំលោភ លើសេរីភាពនៃគណបក្សនយោបាយដោយអះអាងថា ផ្លាកគណបក្សទាំងនោះមិនបានទទួលការអនុញ្ញាត ហើយខុសច្បាប់ ។ នៅក្នុងករណីជាច្រើន ពួកអាជ្ញាធរថែមទាំងទម្លាក់ផ្លាកគណបក្សទាំងនោះទៀតផង) ។

## ឃ. ការដាក់កំរិតលើសេរីភាពនៃការបង្កើតសមាគម

រដ្ឋធម្មនុញ្ញមិនកំណត់ការដាក់កំរិតលើសេរីភាពនៃការបង្កើតសមាគមទេ ។ រដ្ឋធម្មនុញ្ញគ្រាន់តែចែងថា :

> មាត្រា ៤២ CC:
>
> ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិបង្កើតសមាគម និងគណៈបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

ប៉ុន្តែរដ្ឋធម្មនុញ្ញពុំបានចែងថា ច្បាប់អាចកំណត់សេរីភាពនេះសំរាប់គោលបំណងជាក់លាក់ណាមួយឡើយ ។ ដូច្នេះ មានតែការដាក់កំរិតទូទៅលើសិទ្ធិមនុស្សទាំងអស់ប៉ុណ្ណោះអាចអនុវត្តបាន ដែលប្រការនេះមានចែងនៅក្នុងមាត្រា ៣១ II ២ នៃរដ្ឋធម្មនុញ្ញកម្ពុជា :

> មាត្រា៣១ II ២ CC:
>
> ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់អ្នកដទៃទេឡើយ ។

ដូច្នេះ ច្បាប់អាចដាក់កំរិតបានតែលើសេរីភាពនៃការបង្កើតសមាគម ប្រយោជន៍ដើម្បីការពារសិទ្ធិសេរីភាពរបស់អ្នកដទៃប៉ុណ្ណោះ ។

អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយកំណត់នូវលទ្ធភាពបន្ថែមមួយចំនួនសំរាប់ការដាក់កំរិតនេះ ប៉ុន្តែ វាក៏ហាមប្រាមយ៉ាងច្បាស់លាស់នូវវិធានការនីតិកម្មមួយចំនួន ដែលមានបំណងរារាំងដល់សេរីភាពនៃសហជីពកម្មករផងដែរ:

> មាត្រា២២ I និង II ICCPR:
>
> ២. សិទ្ធិដែលបានចែងខាងលើនេះ អាចប្រើប្រាស់បានដោយសេរី ដរាបណាដែលគ្មានការជំទាស់ដល់ច្បាប់ បញ្ញត្តិក្នុងសង្គមប្រជាធិបតេយ្យ ក្នុងវិស័យរក្សាសន្តិសុខជាតិ របៀបរៀបរយសាធារណៈ ក្នុងវិស័យការពារសីលធម៌ និងសុខុមាលភាពសាធារណៈ ព្រមទាំងការពារសិទ្ធិ និងសេរីភាពអ្នកដទៃ ។ ចំពោះភ្នាក់ងារនគរបាល ឬកងយោធាវិញ ការប្រើប្រាស់សិទ្ធិដូចចែងខាងលើនេះ ត្រូវអនុលោមទៅតាមបញ្ញត្តិច្បាប់នៃក្រសួង ឬរដ្ឋាភិបាលរបស់ខ្លួន ។
>
> ៣. រដ្ឋទាំងអស់ជាភាគីនៃសន្និបាតអំពីអង្គការការងារអន្តរជាតិ ក្នុងឆ្នាំ ១៩៤៨ ដែលប្រជុំពិភាក្សាអំពី "សិទ្ធិសេរីភាពក្នុងការរួមប្រជុំ" ហើយនិង " ការការពារសិទ្ធិក្នុងការរៀបចំពិធីផ្សេងៗ" ពុំអាចយកចំណុចណាមួយក្នុងមាត្រានេះ មកធ្វើជាលេសដើម្បីប្រព្រឹត្តបំពាននឹងបញ្ញត្តិច្បាប់ ដែលបានចែងក្នុងកតិកាសញ្ញានោះឡើយ ។

មាត្រា៦ នៃច្បាប់ស្តីពីគណៈបក្សនយោបាយ គឺជាការដាក់កំរិតសំរាប់គណបក្សទាំងឡាយ ។ ពួកគេត្រូវបានហាមឃាត់មិនឱ្យបង្កើតតំបន់ស្វយ័តមួយនៅក្នុងរដ្ឋរបស់ប្រទេសកម្ពុជា ដើម្បីរៀបចំកងកម្លាំងប្រដាប់អាវុធ និងអនុវត្តសកម្មភាពវិទ្ធង្សនាណាមួយ ប្រឆាំងរបបសេរីពហុបក្ស តាមរយៈការប្រើអំពើហិង្សាដើម្បីគោលបំណងកាន់កាប់អំណាច ។ ការកំណត់ទាំងនេះកំពុងតែការពារយ៉ាងច្បាស់លាស់នូវសន្តិសុខជាតិ និងសិទ្ធិរបស់អ្នកដទៃ ។ ការប្រើអំពើហិង្សា និងការបង្កើតកម្លាំងប្រដាប់អាវុធអាចរំលោភយ៉ាងជាក់ស្តែងនូវសិទ្ធិ ដើម្បីរស់រានមានជីវិត សិទ្ធិទទួលការថែទាំសុខភាព និងសិទ្ធិសេរីភាពនៃសកម្មភាព (សេរីភាពនៃការគំរាមកំហែង ឬការបង្ខិតបង្ខំដើម្បីធ្វើអ្វីមួយ)។

ការដាក់កំរិតមួយទៀតដើម្បីការពារសិទ្ធិរបស់អ្នកដទៃ (មាត្រា៣១ II ៣) ក៏មានចែងនៅក្នុងមាត្រា ៤ (ខ) CERD ផងដែរ :

> មាត្រា ៤ (ខ) CERD:
>
> ... រដ្ឋជាភាគីទាំងឡាយ ... ត្រូវប្រកាសថាខុសច្បាប់ និងហាមឃាត់អង្គការ និងសកម្មភាពឃោសនាដែលមានការចាត់តាំង និងសកម្មភាពឃោសនាផ្សេងៗទៀត ដែលជំរុញ និងញុះញង់ឱ្យមានការរើសអើងពូជសាសន៍ ហើយត្រូវទទួលស្គាល់ថាការចូលរួមក្នុងអង្គការ និងសកម្មភាពទាំងនោះ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ ...

មាត្រានេះថែមទាំងបង្កើតករណីយកិច្ចមួយទៀតសំរាប់រដ្ឋ ដើម្បីហាមឃាត់ និងរំលាយសមាគមណាមួយដែលមានបំណងបន្តលុបបំបាត់ពូជសាសន៍[៥៦] ។

[៥៦] សំរាប់ឧទាហរណ៍បន្ថែម សូមមើលវិបសាយ: www.bayefsky.com (សូមចុចលើ "Document by Theme and Subject Matter" បន្ទាប់មកសូមចុចលើ :"Association-freedom of" ហើយបន្ទាប់មកទៀត សូមចុចលើ "Concluding observation-CERD")

# សេរីភាពក្នុងការបង្កើតសមាគម

| មុខងារ | បណ្តាធាតុផ្សំនានា | | | ការដាក់កំហិត |
|---|---|---|---|---|
| | "សមាគម" | "សេរីភាព" នៃសមាគម | | |
| | | សិទ្ធិរបស់បុគ្គលម្នាក់ៗ | សិទ្ធិរបស់សមាគម | |
| **ការរួបរួមគ្នា** នូវចំណេះដឹង ពតិមាន និងថវិការ របស់បុគ្គលម្នាក់ៗ<br><br>**ការការពារ** សមាជិកក្រុម<br><br>បង្កើនឱកាសឱ្យគេ **ទទួលស្គាល់**-កាលណាចំនួនកាន់តែច្រើន សំលេងកាន់តែខ្លាំង ។ (ការចូលរួម) | ក្រុមមនុស្ស<br><br>ចូលរួមដោយ**ស្ម័គ្រចិត្ត**<br><br>មាន**គោលបំណងរួម**<br><br>**មានរយៈពេលឋិតស្ថេរ**<br><br>មាន**រចនាសម្ព័ន្ធចាត់តាំងមួយ** | សិទ្ធិក្នុងការ...ដោយសេរី<br><br>**បង្កើត**សមាគម<br><br>**ចូលរួម**សមាគម<br><br>**ជាសមាជិក**នៃសមាគម<br><br>**រំលាយ**សមាគម<br><br>**ចាកចេញ**ពីសមាគម | សិទ្ធិក្នុងការ<br><br>ទទួលបាននូវ**បុគ្គលភាពគតិយុត្តិ**<br><br>**ដំណើរការចុះឈ្មោះដ៏ច្បាស់លាស់**<br>• មានលក្ខណៈរហ័ស<br>• ថោក<br>• ត្រួតពិនិត្យដោយច្បាប់<br>• អប្បបរមា នៃចំនួនសមាជិក ?<br>• ពិតមានលំអិតស្តីពីតួនាទី?<br><br>**មុខងារដោយសេរី**<br>• បង្កើនការគាំទ្រផ្នែកហិរញ្ញវត្ថុ<br>• ចូលរួមជាមួយអង្គការផ្សេងទៀត<br>• បញ្ញត្តិកិច្ចការផ្ទាល់ខ្លួន<br>• អនុវត្តនូវសកម្មភាពនានា (ជាពិសេសការធ្វើកូដកម្ម) | **សិទ្ធិអ្នកដទៃ**<br>(មាត្រា៤២ I ២ និង៣១ II ២ CC)<br><br>**សន្តិសុខជាតិ**<br><br>**សណ្តាប់ធ្នាប់ សុវត្ថិភាពសាធារណៈ**<br><br>**សីលធម៌ និងសុខមាលភាពសាធារណៈ**<br>(មាត្រា២២ II ១ ICCPR)<br><br>ឧទាហរណ៍:<br>មាត្រា ៦ នៃច្បាប់ស្តីពីគណៈបក្សនយោបាយ<br>-មាត្រា៤ ខ ICERD ។ |

## ? សំនួរសិក្សាទី ១៥

នៅខែមករា ២០០៣ ក្រុមបាតុករខ្មែរដែលប្រើហិង្សា បានវាយប្រហារទៅលើហាងទំនិញ និង អាគាររបស់ជនជាតិថៃ ហើយបណ្តេញជនជាតិថៃ ដែលក្នុងករណីខ្លះពួកគេទទួលរងការឈឺចាប់នៅពេលដែលលោតចេញតាមបង្អួចចុះមកដី ។
ប៉ូលីសមិនបានបញ្ឈប់ក្រុមបាតុករទេ ។

ក. តើសិទ្ធិជាមូលដ្ឋានរបស់ភាគីទាំងឡាយដែលពាក់ព័ន្ធមានអ្វីខ្លះ?

ខ. តើអ្វីខ្លះជាមូលហេតុនៃអំពើហិង្សានេះ?

គ. តើមានបទបញ្ញាច្បាប់អ្វីខ្លះដែលហាមឃាត់ការផ្សព្វផ្សាយអំពីការស្អប់ជាតិសាសន៍នៅប្រទេសកម្ពុជា?